ជំពូកទី1 លក្ខណៈទូទៅ

1.1-សេចក្តីផ្តើម

ក្រោមនយោបាយឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជាបានធ្វើសមាហរណកម្មផ្ទៃក្នុង ហើយទទួលបាននូវសុខសន្តិភាពពេញលេញ និងស្ថេរភាពនយោបាយ ព្រមទាំងបានធ្វើសមាហរណកម្មទៅក្នុងតំបន់ និងអន្តរជាតិ ដែលធ្វើឲ្យប្រទេសមានការរីកចំរើនគួរឲ្យកត់សំគាល់ពីសំណាក់ស្ថាប័នក្នុងស្រុក និងអន្តរជាតិ។ យ៉ាងណាមិញ ពាណិជ្ជកម្មនាំចេញ-នាំចូលនៅចន្លោះឆ្នាំ2000-2007 មានកំណើនប្រចាំឆ្នាំជាមធ្យមដល់ទៅប្រមាណ19%(ADB 2008)។ ពាណិជ្ជកម្មនាំចេញ-នាំចូលនេះ មានទំនាក់ទំនងយ៉ាងស្និតរមួតជាមួយវិស័យដឹកជញ្ជូន ដែលការអភិវឌ្ឍន៍ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវគោកជាកត្តាសំខាន់សម្រាប់ទំនាក់ទំនងក្នុងស្រុក និងជាមួយប្រទេសជិតខាង។ ចំណែកឯការដឹកជញ្ជូនតាមផ្លូវទឹកវិញ គឺជាមធ្យោបាយមួយប្រកបដោយលក្ខណៈសេដ្ឋកិច្ច សម្រាប់ផ្សារភ្ជាប់ពាណិជ្ជកម្មជាមួយបណ្តាប្រទេសនានាក្នុងសហគមន៍អាស៊ាន ក៏ដូចជាពិភពលោក ដែលរាជរដ្ឋាភិបាលបាន និងកំពុងយកចិត្តទុកដាក់ក្នុងចំណោមយុទ្ធសាស្ត្រអភិវឌ្ឍន៍នានា។ ចំពោះការដឹកជញ្ជូនតាមផ្លូវទឹកដែលមាននាពេលបច្ចុប្បន្នវិញ គេសង្កេតឃើញមានកំពង់ផែធំៗមួយចំនួននៅតាមបណ្តោយឆ្នេរសមុទ្រ ចាប់ពីកំពង់ផែអន្តរជាតិខេត្តព្រះសីហនុទៅផ្នែកខាងក្នុងនៃឈូងសមុទ្រថៃ(ទិសខាងជើង)តែប៉ុណ្ណោះ។
ក្នុងចំណោមខេត្តនៅតាមបណ្តោយឆ្នេរសមុទ្រកម្ពុជាទាំងបួន ខេត្តកំពតដែលមានទីតាំងនៅក្បែរមាត់ទ្វារឈូងសមុទ្រថៃ ហើយក្បែរកោះត្រល់ នៅមិនទាន់មានកំពង់ផែសម្រាប់ការនាំចេញ-ចូលទំនិញខ្នាតអន្តរជាតិនៅឡើយទេ។ យ៉ាងណាមិញ ខេត្តនេះមានរោងចក្រវារីអគ្គិសនី ដែលនឹងផ្តល់ថាមពលអគ្គិសនី(ថាមពលកកើតឡើងវិញ)សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងវិស័យនានា ជាពិសេសគឺវិស័យឧស្សាហកម្ម ដែលធ្វើឲ្យខេត្តកំពតមានសក្តានុពលសម្រាប់គំរោងវិនិយោគ និងការអភិវឌ្ឍន៍។

ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ច្រើនវិស័យ គួបផ្សំជាមួយសក្តានុពលរបស់ខេត្តកំពតផងនោះ នៅឆ្នាំ2006 ក្រុមហ៊ុន កំពត ផត(KAMPOT PORT CO., LTD.) បានស្នើគំរោងវិនិយោគបង្កើតកំពង់ផែអន្តរជាតិកំពត ដែលមានទីតាំងក្នុងឃុំកោះតូច និងឃុំបឹងទូក ស្រុកកំពត(បច្ចុប្បន្នស្រុកកំពតត្រូវបានប្តូរឈ្មោះមកជាស្រុកទឹកឈូ[1]) ខេត្តកំពត។ បន្ទាប់មកទៀត ក្រុមហ៊ុនកំពត ស្ពេសសល អេកូណូមិកហ្សូន ឌូអិលធីឌី (KAMPOT SPECIAL ECONOMIC ZONE CO., LTD) បានស្នើគំរោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសកំពតនៅទីតាំងអមជាប់ជាមួយគំរោងកំពង់ផែអន្តរជាតិកំពត។ តាមរយៈគំរោងវិនិយោគទាំងពីរនេះ គេរំពឹងថាខេត្តកំពតកាន់តែមានសក្តានុពលជាច្រើនបន្ថែមទៀត ព្រមទាំងមានកាលានុវត្តភាពជាតំបន់អភិវឌ្ឍន៍ឧស្សាហកម្ម ពាណិជ្ជកម្ម និងទីក្រុងណេប ដែលអាចធ្វើឲ្យមានកំណើនប្រជាពលរដ្ឋមុខរបរ បំណូលបើប្រើនវិស័យ ដែលបង្ហាញឲ្យមានកំណើនសេដ្ឋកិច្ចតំបន់ ក៏ដូចជាសេដ្ឋកិច្ចជាតិ។

គំរោងទាំងពីរនេះជាគំរោងដែលមានទីតាំងជាប់គ្នា ដែលគ្រោងនឹងអភិវឌ្ឍនៅលើតំបន់ចាក់បំពេញនៅក្នុងសមុទ្រ។ ម្យ៉ាងទៀត ដើម្បីបង្កលទ្ធភាពឲ្យនាវាតូចធំអាចចេញចូលកំពង់ផែបាន ក្រុមហ៊ុនត្រូវធ្វើការបូមបង្កើតឆ្លងនាវាចេញ-ចូល ដែលល្បាប់បូមបាននេះ នឹងត្រូវយកមកចាក់បំពេញនៅទីតាំងបង្កើតតំបន់សេដ្ឋកិច្ចពិសេសកំពត និងកំពង់ផែអន្តរជាតិកំពត។ ក៏ប៉ុន្តែ ការបូមបង្កើតឆ្លងនេះ អាចបង្កឲ្យមានហេតុប៉ះពាល់បរិស្ថានមួយចំនួន ដែលនាំឲ្យមានការបារម្ភថានឹងអាចប៉ះពាល់ទៅលើបរិស្ថានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាសុខភាព និងសុខុមាលភាពសាធារណៈផងដែរ។

[1]ឯកសារយោង2

អាស្រ័យហេតុនេះ ក្រុមហ៊ុនបានសម្រេចសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើការបូមខ្សាច់បង្កើតឃ្លងនាវាចេញ-ចូល និងការចាក់ខ្សាច់បំពេញតំបន់សេដ្ឋកិច្ចពិសេស និងកំពង់ផែកំពត។

ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ បានផ្តោតជាសំខាន់ទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

-ការសិក្សាអំពីសណ្ឋានបាតសមុទ្រ

-ការសិក្សាអំពីចរន្តទឹក និងការសាយភាយ

-ការសិក្សាអំពីជីវៈចម្រុះដែលមានស្រាប់នៅក្នុង និងក្បែរតំបន់គំរោង

-ការសិក្សាលើធនធានសេដ្ឋកិច្ច-សង្គមដែលមានស្រាប់នៅក្បែរតំបន់គំរោង

ការសិក្សា និងវិភាគលើចំណុចទាំងឡាយខាងលើនេះ នឹងមានរៀបរាប់ក្នុងរបាយការណ៍ ដែលមានចែកជាជំពូកដូចខាងក្រោម៖

ជំពូកទី1 លក្ខណៈទូទៅ

ជំពូកទី2 ក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធ

ជំពូកទី3 ការពិពណ៌នាគំរោង

ជំពូកទី4 ស្ថានភាពបរិស្ថានដែលមានស្រាប់

ជំពូកទី5 ការប្រឹក្សាពិគ្រោះយោបល់សាធារណៈ

ជំពូកទី6 ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ជំពូកទី7 ផែនការគ្រប់គ្រងបរិស្ថាន

ជំពូកទី8 សន្និដ្ឋាន និងអនុសាសន៍

1.2-និយមន័យពាក្យ

ដើម្បីជាការសម្រួលក្នុងការសរសេររបាយការណ៍នេះ ពាក្យមួយចំនួនត្រូវបានឲ្យនិយមន័យដូចខាងក្រោម៖

«គំរោង»៖ សំដៅលើការបូមខ្សាច់បង្កើតឃ្លងនាវាចេញ-ចូល ដោយយកខ្សាច់-ភក់ដែលបូមបានមកចាក់ក្នុងតំបន់ចាក់បំពេញរបស់ក្រុមហ៊ុនកំពតផត(KAMPOT PORT CO., LTD.) លើកលែងពាក្យគំរោងណាដែលមានបញ្ជាក់ឈ្មោះ។

«ការសិក្សា»៖ សំដៅលើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោង លើកលែងពាក្យសិក្សាណាដែលមានបញ្ជាក់ខ្លឹមសារខាងក្រោយ។

«តំបន់បូម»៖ សំដៅលើទីតាំងដែលត្រូវបូមបង្កើតឃ្លងនាវាចេញចូល។

«តំបន់ចាក់បំពេញ»៖ សំដៅលើតំបន់ដែលត្រូវចាក់ខ្សាច់-ថ្ម-ដី-ភក់ បំពេញរបស់ក្រុមហ៊ុន សម្រាប់ជាទីតាំងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសសកំពត និងកំពង់ផែអន្តរជាតិដែលមានទីតាំងស្ថិតនៅក្នុងឃុំកោះតូច និងឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត។

«តំបន់គំរោង»៖ សំដៅលើតំបន់បូម និងតំបន់ចាក់បំពេញ។

«ក្រុមហ៊ុន»៖ សំដៅលើក្រុមហ៊ុនកំពត ផត ដែលជាម្ចាស់គំរោង លើកលែងពាក្យក្រុមហ៊ុនណាដែលមានបញ្ជាក់ឈ្មោះ។

រាល់លេខនិយាមការនៅក្នុងរបាយការណ៍នេះ រួមបញ្ចូលទាំងទិន្នន័យក្នុងរបាយការណ៍IESIA2006 [2] និង EIA2009[3] ត្រូវបានបំលែង-ប្រើប្រាស់ Datum: WGS 84 ដើម្បីតំរូវតាមផែនទីតំបន់គំរោងរបស់ម្ចាស់គំរោង (រូបភាព 3.2)។

[2]ឯកសារយោង9

រាល់តួលេខប្រើប្រាស់ក្នុងរបាយការណ៍នេះត្រូវបានសរសេរតាមប្រព័ន្ធលេខអារ៉ាប់។

1.3-គោលបំណង និងទិសដៅនៃការសិក្សា

គោលបំណងសំខាន់នៃការសិក្សានេះ គឺសំដៅកែលំអ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថានធម្មជាតិ ក៏ដូចជាសង្គមនៅក្បែរតំបន់គំរោងឲ្យបានសមស្រប ដោយអនុលោមទៅតាមច្បាប់កិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ច្បាប់គ្រប់គ្រងធនធានទឹក និងច្បាប់បញ្ញត្តិផ្សេងៗទៀត។

ការសិក្សានេះ មានទិសដៅសំខាន់ៗដូចតទៅ៖

-សិក្សាស្វែងយល់ពីធនធានធម្មជាតិ ដូចជាពពួកជីវៈចម្រុះតាមតំបន់ឆ្នេរ និងក្នុងទឹកដែលមានស្រាប់នៅតំបន់គំរោង។

-ពិនិត្យ និងសិក្សាតំបន់គំរោង និងតំបន់ជុំវិញគំរោង ដែលអាចទទួលរងឥទ្ធិពលដោយផ្ទាល់ ឬប្រយោលពីគំរោង។

-ប៉ាន់ប្រមាណនូវហេតុប៉ះពាល់លើធនធានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមដែលអាចបណ្តាលមកពីគំរោង។

-កំណត់សក្តានុពលនៃហេតុប៉ះពាល់បរិស្ថានវិជ្ជមាន និងអវិជ្ជមានដែលអាចកើតមានដោយសារគំរោង។

-កំណត់វិធានការកាត់បន្ថយនូវហេតុប៉ះពាល់បរិស្ថានអវិជ្ជមានលើបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ចសង្គម។

-រៀបចំផែនការគ្រប់គ្រងបរិស្ថាន ដើម្បីចៀសវាង ឬកាត់បន្ថយផលប៉ះពាល់ដែលបានព្រាងទុក។

1.4-វិធីសាស្ត្រសិក្សា

ការសិក្សានេះ ត្រូវបានអនុវត្តតាមវិធីសាស្ត្រដូចមានបញ្ជាក់ខាងក្រោម៖

-ប្រមូលទិន្នន័យ និងព័ត៌មានគ្រឹះទាក់ទងនឹងក្រុមហ៊ុនម្ចាស់គំរោង និងរបាយការណ៍នានាទាក់ទងនឹងគំរោង

-យល់ពីគោលបំណងនៃការសិក្សា និងលើកចំណាទ និងមញ្ហានានាដែលអាចកើតចេញពីគំរោង

-បង្កើតកម្រងសំនួរ និងCheck list

-ចុះប្រមូលទិន្នន័យដល់ទីតាំងភូមិសាស្ត្ររបស់គំរោង និងប្រឹក្សាពិគ្រោះយោបល់ជាសាធារណៈជាមួយមេភូមិ មេឃុំ និងស្ថាប័នដែលពាក់ព័ន្ធនានា

-ចុះសិក្សាពីបរិស្ថានធម្មជាតិដែលមានស្រាប់ ដូចជាពពួកជីវៈចម្រុះរស់នៅក្នុងទឹកសមុទ្រ(ពពួកត្រី ស្មៅសមុទ្រ ផ្កាថ្ម សារាយជាដើម) ពពួកសត្វរស់នៅតាមបណ្តាយឆ្នេរ ព្រៃកោងកាង

-ការចុះសិក្សាទៅលើស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋក្បែរតំបន់គំរោង

-ការសិក្សាគុណភាពទឹកតំបន់គំរោង

-វិភាគទិន្នន័យដែលប្រមូលបាន និងរៀបរាប់អំពីបរិស្ថានធម្មជាតិ និងសង្គមដែលមានស្រាប់ រួចធ្វើការប៉ាន់ប្រមាណអំពីការប្រែប្រួលបរិស្ថានដែលអាចកើតមានដោយសារគំរោង

-កំណត់ឥទ្ធិពលហេតុប៉ះពាល់អវិជ្ជមាន និងវិជ្ជមានដែលបណ្តាលមកពីសកម្មភាពគំរោង

-រិះរកវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន និងអនុសាសន៍ផ្សេងៗ ដោយស្រង់យកសំណូមពរពីប្រជាពលរដ្ឋ និងស្ថាប័នដែលពាក់ព័ន្ធតំបន់គំរោង

-រៀបចំផែនការគ្រប់គ្រងបរិស្ថាន ដោយមានការអង្កេត តាមដាន និងត្រួតពិនិត្យ នូវរាល់សកម្មភាពរបស់គំរោង

-ធ្វើការសន្និដ្ឋានរួម និងអនុសាសន៍នានាទាក់ទងនឹងការអនុវត្តន៍គំរោង

[3]ឯកសារយោង10

រូបភាព 1. 1 គំនូសបំព្រួញវិធីសាស្ត្រសិក្សាស្រាវជ្រាវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន



Draft